# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ...២៦៨...ស.ខល

ថ្ងៃពុធ ៩កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**
**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការពង្រឹងការគ្រប់គ្រងចត្តាឡីស័ក និងការអនុវត្តវិធានការសុខភាពសាធារណៈ បង្ការការឆ្លងដោយចំហេតុនូវវីរុសកូវីដ-១៩ ដើម្បីកាត់ផ្តាច់ខ្សែចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ទ្រង់ទ្រាយធំ។

**យោង៖** ការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់**ជ្រាបថា ក្នុងពេលកន្លងមកនេះ ការងារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការគ្រប់គ្រងពលករចំណាកស្រុកមកពីប្រទេសថៃ ក្នុងរយៈពេលកន្លងទៅ មានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ។ ទោះជាយ៉ាងនេះក្តី ដោយសារមានខេត្តខ្លះ មានការដាក់ពលករមកពីប្រទេសថៃធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ អាចមានចំនួនលើសពីបន្ទុកដែលអាចគ្រប់គ្រងបាន ដែលជាការព្រួយបារម្ភសម្រាប់ការងារគ្រប់គ្រងអ្នកធ្វើចត្តាឡីស័កនេះ ខ្ញុំសូម **ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់** យកចិត្តទុកដាក់ខ្ពស់ជាបន្តទៀត ក្នុងការគ្រប់គ្រងអ្នកធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ និងការគ្រប់គ្រងអ្នកដំណើរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា តាមច្រកអន្តរជាតិ និងតាមច្រករបៀងទាំងអស់នៅតាមព្រំប្រទល់កម្ពុជា-ថៃ ឱ្យបានហ្មត់ចត់ជាទីបំផុត ដោយអនុវត្តតាមការណែនាំ មានដូចតទៅ៖

- សម្រាប់ពលករមកពីប្រទេសថៃ ចូលតាមច្រកអន្តរជាតិ និងតាមច្រករបៀងទាំងអស់នៅតាមព្រំប្រទល់កម្ពុជា-ថៃ ត្រូវធ្វើការវាស់កំដៅ និងបំពេញសេចក្តីប្រកាសព័ត៌មានសុខភាពអ្នកដំណើរជាមុន។ ដើម្បីបញ្ចៀសការកកស្ទះនៃការយកវត្ថុសំណាកនៅតាមច្រកចូលសម្រាប់ពលករមកពីប្រទេសថៃ ក្រោយពីពិនិត្យសុខភាព៖

  -ក្នុងករណីសង្ស័យ ត្រូវយកវត្ថុសំណាកភ្លាមៗ ដើម្បីផ្ញើមកធ្វើវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ ឬនៅមន្ទីរពេទ្យខេត្តសៀមរាប ហើយដាក់ឲ្យនៅដាច់ដោយឡែកដើម្បីរង់ចាំលទ្ធផលវិភាគសិន។ បើលទ្ធផលវិជ្ជមានវីរុសកូវីដ-១៩ ត្រូវព្យាបាលនៅមន្ទីរពេទ្យខេត្តតែម្តង តែបើអវិជ្ជមាន ទើបអនុញ្ញាតឲ្យដឹកជញ្ជូនតាមរថយន្តកងទ័ពទៅតាមមូលដ្ឋានរាជធានី-ខេត្ត ដែលគាត់ស្នាក់នៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ។

  -សម្រាប់អ្នកដែលមិនមានការសង្ស័យ ត្រូវដឹកជញ្ជូនភ្លាមៗទៅតាមមូលដ្ឋានរាជធានី-ខេត្ត ដោយមធ្យោបាយកងទ័ព និងត្រូវយកវត្ថុសំណាកនៅតាមទីកន្លែងធ្វើចត្តាឡីស័កនៅខេត្តនោះតែម្តង។

- ត្រូវផ្គត់ផ្គង់ម្ហូបអាហារ និងរបស់ប្រើប្រាស់សម្រាប់អ្នកធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមមណ្ឌលចត្តាឡីស័ករាជធានី-ខេត្ត ខណ្ឌ ឬស្រុក ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានឧបត្ថម្ភ គាំទ្រជាថវិកា

និងសំភារៈជូនរាជធានី-ខេត្ត រួចហើយ ព្រមទាំងបានឯកភាពប្រគល់ជូនអាជ្ញាធរថ្នាក់ក្រោមជាតិ ឱ្យទទួលខុសត្រូវតាមដាន និងគ្រប់គ្រងអ្នកធ្វើចត្តាឡីស័កនៅតាមមូលដ្ឋានក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

- ប្រសិនបើមានពលករលួចចូលមកពីប្រទេសថៃ ដោយមិនបានត្រួតពិនិត្យនៅព្រំដែន និងមិនបានធ្វើដំណើរតាមមធ្យោបាយកងទ័ព សុំអាជ្ញាធររាជធានី-ខេត្ត ធ្វើការណែនាំទៅស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដើម្បីរៀបចំឲ្យធ្វើចត្តាឡីស័កនៅផ្ទះ ឬនៅកន្លែងដែលមូលដ្ឋានរៀបចំឲ្យ និងត្រូវយកវត្ថុសំណាករបស់ពួកគាត់ធ្វើការវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ ឬមន្ទីរពេទ្យខេត្តសៀមរាប។ ក្នុងករណី ដែលមានពលករមកពីប្រទេសថៃបានទៅដល់ផ្ទះសម្បែងរបស់ពួកគាត់រួចហើយ អាជ្ញាធរមូលដ្ឋាន ត្រូវគ្រប់គ្រងឱ្យបានហ្មត់ចត់ និងក្ដាប់ឲ្យបាននូវការធ្វើចត្តាឡីស័កនៅតាមផ្ទះរបស់ពួកគាត់ និងត្រូវមានការតាមដានសុខភាពពួកគាត់ជាប្រចាំ។
- ណែនាំ និងចាត់វិធានការតាមដានការអនុវត្តវិធានការចត្តាឡីស័កខាងលើនេះ ឲ្យបានហ្មត់ចត់ជាទីបំផុត ជៀសវាងការបេះតចេញពីទីកន្លែងធ្វើចត្តាឡីស័ក ដោយយើងមិនបានដឹង ចាំបាច់ត្រូវចាត់តាំងកម្លាំងសមត្ថកិច្ចតាមដាន និងឃ្លាំមើលពួកគាត់ជាប់ជាប្រចាំ ជាពិសេសអាជ្ញាធរភូមិ ឃុំ ស្រុក សមាគមនារី តំណាងសហគមន៍ និងក្រុមគ្រួសារ ត្រូវបានលើកទឹកចិត្តឲ្យចូលរួមតាមឃ្លាំមើលអ្នកធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវ និងគ្រប់ចំនួន ១៤ថ្ងៃ ដូចដែលយើងធ្លាប់បានធ្វើរួចមកហើយ សម្រាប់ពលករដែលបានវិលត្រឡប់មកពីប្រទេសថៃ កាលពីខែមេសា ឆ្នាំ២០២០។
- ណែនាំ និងចាត់វិធានការ ជំរុញប្រជាជនក្នុងសហគមន៍ឱ្យយកចិត្តទុកដាក់រក្សាអនាម័យឲ្យបានស្អាតជានិច្ច ដោយលាងដៃជាមួយទឹកស្អាតនឹងសាប៊ូ អាល់កុល ឬជែលលាងដៃ ឱ្យបានញឹកញាប់ ប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវជាប្រចាំ (ឬនៅក្នុងករណីចាំបាច់) ឬប្រើកន្សែង ក្រម៉ា ឬក្រដាសជូតមាត់ ដើម្បីខ្ទប់មាត់ និងច្រមុះពេលក្អក-កណ្ដាស់។
- ត្រូវតាមដានសុខភាពអ្នកធ្វើចត្តាឡីស័ក ឲ្យបានជាប់ជាប្រចាំ និងត្រូវរាយការណ៍ឱ្យបានទាប់ហាសជូនដល់អាជ្ញាធរពាក់ព័ន្ធ ឬមន្ទីរសុខាភិបាលខេត្ត ឬមណ្ឌលសុខភាពដែលនៅជិតៗ ឬក្រុមឆ្លើយតបបន្ទាន់តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ១១៥ (ដោយមិនគិតថ្លៃ) របស់ក្រសួងសុខាភិបាល រាល់ពេលសង្កេតឃើញមានករណីសង្ស័យចូលក្នុងនិយមន័យនៃជំងឺកូវីដ-១៩។
- អាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវចាត់តាំងកម្លាំងមានសមត្ថកិច្ច ធ្វើការយាមកាម ឲ្យបានដិតដល់ ព្រមទាំងក្រុមការងារតាមដាន និងត្រួតពិនិត្យជាប់ជាប្រចាំ នូវការអនុវត្តវិធានការបង្ការការឆ្លងជាយថាហេតុនូវវីរុសកូវីដ-១៩ ដោយការទទួលខុសត្រូវខ្ពស់។
- ប្រសិនបើបុគ្គលណា មិនគោរពអនុវត្តតាមវិធានការចត្តាឡីស័កចំនួន ១៤ថ្ងៃ ឬរត់ចេញ ឬគេចវេសពីការធ្វើចត្តាឡីស័ក អាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ដោយមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរខេត្ត ត្រូវចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន ដោយមានការពិន័យអន្តរការណ៍ ពី ២០០,០០០រៀល ទៅ ១,០០០,០០០ រៀល និងទោសព្រហ្មទណ្ឌទៅតាមច្បាប់កំណត់ដែលមានចែងក្នុងអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ មេត្តាអនុវត្តឱ្យបានម៉ឺងម៉ាត់នូវការណែនាំខាងលើនេះ ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងកាត់ផ្ដាច់ខ្សែចម្លងវីរុសដ៏កាចសាហាវនេះ មិនឱ្យមានការចម្លងចូលក្នុងសហគមន៍យើង។

សូម ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការគោរពអានដ៏ជ្រាលជ្រៅពីខ្ញុំ។

ម៉ម_ប៊ុនហេង

ចម្លងជូន៖

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ